# ការបង្កើតទស្សនៈនៃគណនេយ្យភាព៖ ករណីនៅកម្ពុជា

លោក ហ៊ាង វុទ្ធី ពិភាក្សាពីទស្សនៈនៃគណនេយ្យភាពក្នុងវិស័យសាធារណៈ ដោយយោងតាមគំរូនៃប្រទេសលោកខាងលិច និងក្នុងបរិបទនៃការអនុវត្តន៍អភិបាលកិច្ចនៅកម្ពុជា ។*

## កិច្ចប្រឹងប្រែងធ្វើកំណែទម្រង់របស់រដ្ឋាភិបាល និងចំណងទាក់ទងជាមួយគណនេយ្យភាព

គណនេយ្យភាពក្នុងវិស័យសាធារណៈ បានក្លាយជាក្តីបារម្ភយ៉ាងធំរបស់រដ្ឋាភិបាលកម្ពុជា និងសហគមន៍អ្នកផ្តល់ជំនួយក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយគេឃើញមានលើកឡើងកាន់តែញឹកញាប់នៅក្នុងរបាយការណ៍របស់រដ្ឋាភិបាល សុន្ទរកថាផ្លូវការ និងរបៀបវារៈរបស់អ្នកផ្តល់ជំនួយទាក់ទិននឹងអភិបាលកិច្ចល្អ ការកាត់បន្ថយភាពក្រីក្រ វិមជ្ឈការ និងការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យ ។ ជាទ្រឹស្តី គណនេយ្យភាពត្រូវមានជាចាំបាច់ ដើម្បីអាចផ្តល់សេវាមានចីរភាព និងកាត់បន្ថយភាពក្រីក្រ ហើយត្រូវដាក់បង្កប់នៅក្នុងគោលនយោបាយ និងការអនុវត្តន៍ ។ ការបង្កើត និងអនុវត្តន៍គោលនយោបាយស្តីពីការផ្តល់សេវា ជាដំណើរការនយោបាយ និងការរៀបចំផ្នែកបច្ចេកទេស ។ ហេតុនេះ ការសំរេចបានគណនេយ្យភាព និង-ជោគជ័យនៃការផ្តល់សេវាអំណោយផលដល់អ្នកក្រ តំរូវឱ្យមានការយល់ដឹងពីបច្ចេកទេស និង ដំណើរការនយោបាយជាក់ស្តែង ។ ប៉ុន្តែកង្វះការយល់ដឹងពីបរិបទនៃ គណនេយ្យភាព នាំឱ្យមានភាពមិនស៊ីសង្វាក់គ្នា និងភាពជាម្ចាស់មិនច្បាស់លាស់របស់រដ្ឋាភិបាលក្នុងការបង្កើត និងអនុវត្តន៍គោលនយោបាយស្តីពីការផ្តល់សេវាអំណោយផលដល់អ្នកក្រ ។ នៅគ្រប់លំដាប់ថ្នាក់ក្នុងជួររដ្ឋាភិបាល គេរកឃើញភាពស៊ីគ្នាមួយ គឺមន្ត្រីភាគច្រើន តែងបកស្រាយពាក្យគណនេយ្យភាពទៅតាមបរិបទការងាររបស់ខ្លួន ដោយមានយោងតិចតួច រឺគ្មានសោះទៅដល់អត្ថន័យស្តង់ដារមានឯកសារបញ្ជាក់របស់ពាក្យនេះ (មានឯកសារជិតបោះផ្សាយមួយរបស់ វបសអ) ។ តំរូវការកសាងយន្តការគណនេយ្យភាពអំណោយផលដល់អ្នកក្រ វាកាន់តែស្រួចស្រាវឡើងក្នុងបរិបទអភិបាលកិច្ចដូចនៅកម្ពុជា ដែលអត្ថបទនេះនឹងពិពណ៌នាថា ជារបបមេកើយ-កូនចៅសម័យថ្មី ហើយដែល Brinkerhoff and Goldsmith (2002: 40) បានកំនត់និយមន័យថា ជា "ប្រព័ន្ធចំរុះនៃការគ្រប់គ្រងរបស់រដ្ឋាភិបាល ដែល-មាន ស្រទាប់លើសមហេតុផលល្អ-និងស្របច្បាប់នៅគ្របពីលើចំណងទាក់ទង ស្នេកស្នេះតាមបែបបុគ្គល ដែល-ជាចរិតលក្ខណៈនៃការគ្រប់គ្រងរបៀបមេកើយ-កូនចៅ" ។

ដើម្បីស្វែងយល់ពីគណនេយ្យភាព ត្រូវធ្វើការវិភាគថ្លឹងថ្លែងផ្តោតលើ (ក) ទំនាក់ទំនងរវាងតួអង្គនីមួយៗ និង (ខ) រចនាសម្ព័ន្ធ និងប្រព័ន្ធ ដែលជួយជំរុញ និងរារាំងដល់តួអង្គ និងគណនេយ្យភាពរបស់ពួកគេ ។ គណនេយ្យភាពផ្តោតលើស្ថាប័ន សំដៅដល់គណនេយ្យភាពរបស់អ្នកណាចំពោះអ្នកណា និងសំរាប់អ្វី ដែលជារឿយៗ នាំឱ្យមានទំនាក់ទំនងតតួរវាងបុគ្គលឋានៈទាប និងបុគ្គលឋានៈខ្ពស់ ។ ប៉ុន្តែអត្ថបទនេះបានរំលេចថា គណនេយ្យភាពវាស្មុគស្មាញ ជាងរឿងតួអង្គពីរនាក់ដែលចាប់គ្នាឱ្យទទួលខុសត្រូវទៅវិញទៅមកនោះទៀត ។ គណនេយ្យភាពក៏បានកំណត់ឡើងដោយផ្អែកលើបែបបទ ដែលប្រព័ន្ធអភិបាលកិច្ចធំទូលាយ (រួមមានសកម្មភាពនយោបាយ និងបច្ចេកទេស) វាជះឥទ្ធិពលទៅលើឥរិយាបថ និងការយល់ឃើញរបស់តួអង្គទាំងនេះ ។ ឧទាហរណ៍ ការយល់ឃើញថា បញ្ហារដ្ឋបាលអាចដោះស្រាយបានសក្តិសិទ្ធិជាង តាមរយៈទំនាក់ទំនងបុគ្គលច្រើនតែក្លាយជាការអនុវត្តន៍ជាក់ស្តែង និងបង្កើតការមិនទុកចិត្តគ្នានៅក្នុងមុខងារការិយាល័យជាផ្លូវការ ។ សំរាប់កម្ពុជាដែលជាប្រទេសមានប្រពៃណីនៃទំនាក់ទំនងមេកើយ-កូនចៅ ការយល់ដឹងពី បែបបទដែលការចរចាក្រៅផ្លូវការ និងបណ្តាញខាងនយោបាយ វាជះឥទ្ធិពលដល់ទំនាក់ទំនង និងរចនាសម្ព័ន្ធអភិបាលកិច្ចផ្លូវការ គឺសំខាន់ខ្លាំងណាស់សំរាប់អ្នកធ្វើកំណែទំរង់គោលនយោបាយ និងអ្នកអនុវត្ត ។ តើវត្តមានប្រព័ន្ធមេកើយ-កូនចៅ សម័យថ្មី វាធ្វើឱ្យលាយចូលគ្នាបែបណានូវរបៀបរបបអភិបាលកិច្ចផ្លូវការ និងក្រៅផ្លូវការ ដើម្បីជះឥទ្ធិពលដល់គណនេយ្យភាព? អត្ថបទនេះ ផ្តោតលើលក្ខណៈក្រៅផ្លូវការខាងលើ ដោយស្វែងយល់ពីវប្បធម៌យូរលង់នៅកម្ពុជានៃបណ្តាញមេកើយ-កូនចៅ ព្រមទាំងធ្វើការស្រាយបង្ហាញថា តើក្នុងពេលថ្មីៗ បណ្តាញនេះបានប្រទាក់ក្រឡាយ៉ាងដូចម្តេចជាមួយនឹងប្រព័ន្ធការិយាធិបតេយ្យសមហេតុផល ។

យោងតាមវិធីសាស្រ្តខាងលើ អត្ថបទនេះមានគោលដៅពីរ គឺ (១) បង្កើនការយល់ដឹងពីគណនេយ្យភាព និង (២) ជួយអ្នករដ្ឋបាលសាធារណៈកម្ពុជា ឱ្យបង្កើនសមត្ថភាពផ្ទាល់ ដើម្បីកំណត់ពីតួនាទីរបស់ខ្លួនចំពោះទំនាក់ទំនងគណនេយ្យភាពនៅក្នុងប្រព័ន្ធរដ្ឋាភិបាល និងដើម្បីយល់ដឹងពីរបៀប របបដែលនយោបាយ និងស្ថាប័នផ្លូវការ ធ្វើអន្តរកម្មចុះឡើង ដើម្បីជះឥទ្ធិពលទៅលើគណៈនេយ្យភាពក្នុងវិស័យសាធារណៈ ។

## ការកំណត់ទស្សនៈរបស់កម្ពុជាស្តីពីគណនេយ្យភាព

ទោះជាគេយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគណនេយ្យភាពក្តី ប៉ុន្តែនៅមានបញ្ហាប្រឈមជាច្រើនដែលរារាំងមិនឱ្យប្រព័ន្ធ និងទំនាក់ទំនងគណនេយ្យភាពសមហេតុផល កើតមានឡើងបាននៅកម្ពុជា ។ ទី១ មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ជាទូទៅមាន ចំណេះដឹងជាក់ស្តែងទូលំទូលាយស្តីពីបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងវិស័យសាធារណៈ ប៉ុន្តែពួកគេខ្វះខាតក្របខ័ណ្ឌគោលគំនិតដ៏រឹងប៉ឹង ដើម្បីធ្វើវិភាគជាលក្ខណៈប្រព័ន្ធ និងធ្វើការកែលំអ ។ ទី២ មន្ត្រីស៊ីវិល និងអ្នកនយោបាយជារឿយៗ នៅយល់ដឹងមិនទាន់ច្បាស់ពីភាពខុសគ្នារវាងគណនេយ្យភាពស្ថាប័ន និងគណនេយ្យភាពបុគ្គល ជាពិសេសនៅក្នុងស្ថាប័នរដ្ឋថ្នាក់ទាប ដែលអាចនាំឱ្យចុះខ្សោយដល់កិច្ចសន្ទនាជាសាធារណៈ ការ-ផ្លាស់ប្តូរមតិពីគោលការណ៍អភិបាលកិច្ចជាមួយប្រជាពលរដ្ឋ និង-

---

* ឯកសារនេះ ផ្អែកលើលទ្ធផលការងារក្នុងគំរោងសិក្សាពីគណនេយ្យភាពរបស់ វបសអ ដែលបានដំណើរការតាំងពីពាក់កណ្តាលឆ្នាំ២០០៥ ។ សំរាប់ការពិភាក្សាលំអិតលើបញ្ហាលើកឡើងក្នុងអត្ថបទនេះ សូមរង់ចាំអាន *ការសិក្សាវិភាគឯកសារស្តីពីគណនេយ្យភាព និងរបបមេកើយ-កូនចៅសម័យថ្មី: ទស្សនៈ និងករណីសិក្សានៅកម្ពុជា* ។ លោក ហ៊ាង វុទ្ធី ជាអ្នកស្រាវជ្រាវនៅ វបសអ ។

ការអនុវត្តន៍គោល នយោបាយ ។

ពាក្យ "accountablility រឺ គណនេយ្យភាព" ប្រើប្រាស់មិនបានរលូនល្អទេ ក្នុងភាសាអង់គ្លេស ហើយនៅពេលបកប្រែជាភាសាខ្មែរ ក៏កាន់តែមានន័យមិនច្បាស់ថែមទៀត ពីព្រោះគ្មានពាក្យសំរាប់បកប្រែឱ្យចំៗ ។ គណនេយ្យភាព គឺជាពាក្យបង្កើតថ្មី[១] តាមការបកប្រែត្រង់ៗនូវមេពាក្យក្នុងភាសាអង់គ្លេស គឺ account = គណនេយ្យ និង ability = ភាព រឺ សភាព ។ និយាយរួម ពាក្យ គណនេយ្យភាព តែងនាំឱ្យគេគិតដល់សភាពនៃគណនេយ្យ ហើយមន្ត្រីរាជការកម្ពុជា តែងផ្សារភ្ជាប់ពាក្យនេះទៅនឹង គណនេយ្យហិរញ្ញវត្ថុ ។ ជាទូទៅគេមិនបានទឹកដល់គោលគំនិតនៃគណនេយ្យភាពខាងស្ថាប័ន និងគណនេយ្យភាពបុគ្គលទេ ហើយមន្ត្រីរាជការក្រុមផ្សេងគ្នា មានការបកស្រាយន័យខុសៗគ្នា ។ ទាំងមន្ត្រីរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានបកស្រាយន័យពាក្យនេះ ដោយសង្កត់ធ្ងន់លើខ្លឹមសារខាងហិរញ្ញវត្ថុ ដែលរួមមាន "តំលាភាព ការត្រួតពិនិត្យ និងការប្រតិបត្តិតាម" និងដែលអាចជាលទ្ធផលនៃការបកប្រែត្រង់ៗក្នុងន័យ "សភាពនៃគណនេយ្យ" ។ ការបកស្រាយបែបនេះ ក៏អាចមកពីអន្តរកម្មជាមួយប្រព័ន្ធគ្រប់គ្រងផ្អែកតាមអ្នកផ្តល់ជំនួយ ដូចជា កម្មវិធីសិលា ជាដើមដែរ ។

## លក្ខណៈពិសេសខាងបច្ចេកទេសនៃគណនេយ្យភាព

លក្ខណៈបច្ចេកទេសនានានៃគណនេយ្យភាព ផ្អែកលើការរៀបចំខាងស្ថាប័ន រឺ ខាងការិយាធិបតេយ្យសមហេតុផល-ស្របច្បាប់ដែលលេចធ្លោ អាចទាយទុកមុន និងកំណត់ច្បាស់ជាផ្លូវការដោយវិធាននិងបទប្បញ្ញត្តិច្បាប់ (ឧ. គោលការណ៍ណែនាំខាងសុខភាពសាធារណៈ ដើម្បីកែលំអសុខភាពមាតា និងទារក លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើស និងតំលើងឋានៈបុគ្គលិក) ហើយវាទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីក្របខណ្ឌអភិបាលកិច្ចសេរី និងបែបបទអនុវត្តន៍ គាំទ្រដោយពួកបស្ចិមប្រទេស ហើយត្រូវជាងខ្ពស់ដោយស្ថាប័នផ្តល់ជំនួយអន្តរជាតិ ។ ក្នុងអត្ថបទនេះ ក្របខណ្ឌផ្សេងៗគឺមានតាំងពីរដ្ឋបាល សាធារណៈបែបប្រពៃណីដែលបានវិវត្តខាងទ្រឹស្តី ការគ្រប់គ្រងសាធារណៈ បែបថ្មី និងសេដ្ឋកិច្ចស្ថាប័នសម័យថ្មី រហូតដល់វិធីសាស្ត្រផ្តោតលើការអភិវឌ្ឍន៍និងផ្អែកលើអ្នកផ្តល់ជំនួយ ដែលមានដូចជា រដ្ឋមានសមត្ថភាពល្អ វិមជ្ឈការ គណនេយ្យភាពខាងនយោបាយនិងសង្គមកិច្ច គណនេយ្យភាពត្រីកោណ និងគណនេយ្យភាពខ្សែបណ្តោយសំរាប់ការចែករំលែកលទ្ធផលជាដើម[២] ។

ក្របខណ្ឌនីមួយៗជះឥទ្ធិពលជាក់លាក់ទៅលើបែបបទអនុវត្តអភិបាលកិច្ចរបស់កម្ពុជា និងចូលរួមចំណែកកំណត់គណនេយ្យភាពនៅក្នុងរបៀបរបបអភិបាលកិច្ច ។ ឧទាហរណ៍ ប្រព័ន្ធរដ្ឋបាលសាធារណៈជាប្រពៃណី (TPA) បាននាំមកនូវគោលគំនិតនៃការិយាធិបតេយ្យសមហេតុផល-ស្របច្បាប់ ដែលក្នុងនេះអ្នករដ្ឋបាលអាចធ្វើការដាច់ដោយឡែកពីអ្នកនយោបាយ (Weber 1965) ។ បើគិតពីគណនេយ្យភាព TPA បានណែនាំពីគោលគំនិតនៃ "ការទទួលខុសត្រូវចំពោះមុខ" និង "ការដាក់អនុវត្តន៍" (Schedler 1999) ។ រីឯក្របខណ្ឌគ្រប់គ្រងសាធារណៈបែបថ្មី (NPM) ផ្តោតលើគោលគំនិត "ទុកឱ្យអ្នកគ្រប់គ្រងធ្វើការគ្រប់គ្រង" (Drucker 1954, 1964) តាមរយៈការធ្វើវិមជ្ឈការសិទ្ធិអំណាចសំរេចអារកាត់ ដើម្បីឱ្យអ្នកគ្រប់គ្រងអាចជ្រើសរើសធាតុចូលផ្សេងៗ (ទោះជាមានកំហិតខាងថវិកាខ្លះៗ) និងវិធីអនុវត្តការងារដើម្បីអាចសំរេចគោលដៅបាន (Clark និង Newman 1993) ។ ក្របខណ្ឌគ្រប់គ្រងសាធារណៈបែបថ្មី (NPM) បកស្រាយន័យ គណនេយ្យភាព តាមរយៈទំនាក់ទំនងម្ចាស់-ភ្នាក់ងារ ហើយកំណត់ថា គណនេយ្យភាពអាចសំរេចបានតាមរយៈសិទ្ធិសំរេចពេញលេញក្នុងការគ្រប់គ្រង ។ គណនេយ្យភាព ក៏ទទួលឥទ្ធិពលផងដែរពីក្របខណ្ឌសេដ្ឋកិច្ចបែបស្ថាប័នថ្មី (NIE) ។ ដោយឈរលើការសន្មតជាមូលដ្ឋានរបស់ពួកនេអូក្លាស៊ិកស្តីពីភាពកំរនៃធនធាន និងតំរូវការប្រកួតប្រជែង NIE បាន ដាក់បញ្ចូលគ្នានូវសារៈសំខាន់នៃព័ត៌មានគំនិតផ្សេងៗ និងចំណាយប្រតិបត្តិ ការជាប់ពាក់ព័ន្ធ ហើយតភ្ជាប់វាទៅនឹងចំណាយផលិតកម្ម និងប្រសិទ្ធភាព ជាទូទៅនៃទីផ្សារដែលជួយជំរុញកំណើន (North 1990) ។ ចំនុចស្នូលនៃ NIE គឺនិយមន័យពិសេសនៃស្ថាប័នដែលបានបូកបញ្ចូលទាំងវិធានធម្មតាៗ និងបទប្បញ្ញត្តិផ្សេងៗ (ជាពិសេស ព័ត៌មាន) ដែលតួអង្គផ្តល់ឱ្យគ្នានៅក្នុងប្រតិបត្តិការដោះដូរខាងសេដ្ឋកិច្ចនិងទីផ្សារ រឺប្រតិបត្តិការដទៃទៀត (North 1990; World Bank 2002) ។ ស្ថាប័នមានប្រសិទ្ធភាពល្អ ជួយកាត់បន្ថយចំណាយប្រតិបត្តិការ និងជំរុញកំណើន ។ គណនេយ្យភាពបែប NIE គឺផ្អែកលើស្ថាប័ន ទីផ្សារ ព័ត៌មាន កិច្ចសន្យា និងជំរើសនានា ។

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍១៩៩០ ទីភ្នាក់ងារអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី បានណែនាំពីវិធីសាស្ត្រជាច្រើន សំរាប់កែលំអការអភិវឌ្ឍន៍នៅក្នុងប្រទេសក្រីក្រ ។ ឧទាហរណ៍ វិមជ្ឈការដែលអនុវត្តនៅក្រោមគោលការណ៍ "រំលែកអំណាច (subsidiarity)" បានផ្តល់ហេតុផលថា មុខងារព្រមទាំងសិទ្ធិអំណាចនិងធនធានផ្សេងៗសំរាប់អនុវត្តតួនាទីនេះ គួរផ្តល់ទៅឱ្យអាជ្ញាធរមូលដ្ឋានថ្នាក់ទាបបំផុតដែលអាចអនុវត្តវាបាន (Breton *et al.* 1998) ។ ក្របខ័ណ្ឌវិមជ្ឈការ ព្យាយាមសំរេចឱ្យបាននូវគណនេយ្យភាពតាមរយៈ "ការពាំនាំរដ្ឋបាល (អ្នកផ្តល់សេវា) ឱ្យខិតទៅជិតប្រជាពលរដ្ឋ (អ្នកទទួលសេវា)" ដែលធ្វើឱ្យប្រជាពលរដ្ឋអាចទាមទារគណនេយ្យភាពទាំងពីអ្នករដ្ឋបាល និងពីអ្នកដឹកនាំជាប់ឆ្នោតនៅក្នុងមូលដ្ឋានយ៉ាងសកម្ម (Manor 1999: 67) ។ ក្របខ័ណ្ឌថ្មីៗនៃ "គណនេយ្យភាពត្រីកោណ" (WB 2004) សំគាល់ឃើញតួអង្គបីប្រភេទសំខាន់ៗគឺ អ្នកកសាងគោលនយោបាយ អ្នកផ្តល់សេវាជួរមុខ និងប្រជាពលរដ្ឋ ។ វិធីសាស្ត្រគណនេយ្យភាពត្រីកោណបង្កើនការយកចិត្តទុកដាក់លើភាពស្អាតស្អំនៃរចនាសម្ព័ន្ធ និងលទ្ធផលនៃសកម្មភាពបុគ្គល ដើម្បីកែលំអគណនេយ្យភាពខាងស្ថាប័ន ។ម្យ៉ាងទៀត វាមិនគ្រាន់តែពិនិត្យលើគណនេយ្យភាពតាមរយៈព្រឹត្តិការណ៍កន្លងហើយ (ext post perspective) នោះទេ ប៉ុន្តែវាថែមទាំងមើលទៅមុខ មុនព្រឹត្តិការណ៍ (ext ante) ទៀតផង ។ ដូច្នេះ គណនេយ្យភាព ត្រូវមានលក្ខណៈពាក់ព័ន្ធល្អទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលព្រឹត្តិការណ៍កើតឡើង ។ យោងតាមក្របខ័ណ្ឌនេះ លទ្ធផលដែលមានគណនេយ្យភាព ត្រូវផុសចេញពី (ក) ការធ្វើប្រតិភូកម្ម (ការចាត់តាំងច្បាស់លាស់) (ខ) ហិរញ្ញវត្ថុ (ផ្តល់ថវិកាគ្រប់គ្រាន់នៅគ្រប់កំរិត) (គ) លទ្ធផលការងារ (នៃមន្ត្រីរាជការក្រសួង និងអ្នកផ្តល់សេវាឯទៀត) (ឃ) ព័ត៌មានស្តីពីលទ្ធផល និង (ង) លក្ខណៈអាចដាក់អនុវត្តបាន (WB 2004:47) ។

## កត្តាក្រៅផ្លូវការប៉ះពាល់ដល់គណនេយ្យភាព

### មូលដ្ឋានគ្រឹះមេកើយ-កូនចៅ

កម្ពុជា គឺជាសង្គមមានទំនាក់ទំនងបែបមេកើយ-កូនចៅ ជាប្រពៃណី ។ នេះជាវប្បធម៌មួយផ្អែកលើឋានានុក្រមសង្គម ដែលកកើតឡើងនៅជុំវិញ

"មិត្តភាពជាស្នូល ដោយក្នុងនេះបុគ្គលមានឋានៈសេដ្ឋកិច្ច-សង្គមកិច្ចខ្ពស់ (មេកើយ) បានប្រើប្រាស់ឥទ្ធិពលនិងធនធានរបស់ខ្លួន ដើម្បីផ្តល់កិច្ចការពារ និង/រឺ ផលប្រយោជន៍ ដល់អ្នកមានឋានៈទាបជាង (កូនចៅ) ហើយជាការតបស្នង កូនចៅនឹងផ្តល់ជំនួយគាំទ្រជាទូទៅ រួមទាំងសេវាផ្ទាល់ខ្លួនផងទៅដល់មេកើយ" (Scott 1977:92) ។ ចរិតលក្ខណៈនៃទំនាក់ទំនងមេកើយ-កូនចៅ មានជាអាទិ៍ (ក) ឋានានុក្រមរឹងមាំ និងបដិការមិនស្មើភាព ដោយមានកូនចៅនៅហែហមជុំវិញមេកើយ (ខ) មេកើយបានប្រមូលបង្គរទុកទ្រព្យសម្បត្តិតាមរយៈការត្រួតត្រាលើធនធានសំខាន់ៗ (គ) ទំនាក់ទំនងផ្អែកលើមនោសញ្ចេតនា ដូចជាសាច់ញាតិ និងក្រុមគ្រួសារ (ឃ) ការស្វែងរកដំណោះស្រាយដោយផ្អែកលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយមេកើយ និង (ង) សីលធម៌ជាប្រពៃណី និងវប្បធម៌ បានក្លាយជាកត្តាជះឥទ្ធិពលទៅលើចរិតនៃទំនាក់ទំនងមេកើយ-កូនចៅ (Weber 1965, 1978; Scott 1977; Eisenstadt and Roniger 1984; Neher 1981; Hanks 1975) ។

របបមេកើយ-កូនចៅនៅកម្ពុជា បានបង្ហាញនូវលក្ខណៈជាច្រើនដូចបានរៀបរាប់ខាងលើ ។ ឋានានុក្រមរឹងមាំ និងបដិការមិនស្មើភាពនៅកម្ពុជាអាចផុសចេញពីការប្រើប្រាស់ "ខ្សែ" និង "ខ្នង" ។ ខ្សែ សំដៅដល់កូនចៅមួយខ្សែដែលពឹងផ្អែកលើកិច្ចការពារ និងការគាំទ្រពី ខ្នង ដែលមានន័យត្រង់ថា "ខ្នងរបស់មនុស្ស" និង ន័យធៀបថា "មេកើយ" ។ ការណែនាំក្នុងសង្គម ជាប្រពៃណីជំរុញឱ្យប្រជាជនកម្ពុជាស្វែងរក ខ្សែ រឺ ខ្នង ដែលមានលក្ខណៈ ស្របគ្នានឹងការសង្កេតថា ទំនាក់ទំនងមេកើយ-កូនចៅត្រូវបានជំរុញឡើង ដោយសារការបរាជ័យរបស់រដ្ឋ និងបណ្តាញគ្រួសារក្នុងការផ្តល់កិច្ចការពារ ដល់បុគ្គល (Scott 1977) ។ ការណែនាំជាប្រពៃណី និងតាមវប្បធម៌នៅ កម្ពុជាដែលពង្រឹងភក្តីភាពរវាងមេកើយ-កូនចៅ រួមមានការកសាងកុងសង់ស៊ុស និងការជៀសវាងការតទល់ដោយផ្ទាល់ជាមួយអ្នកមានអំណាច រឺ អ្នកឋានៈខ្ពស់ ។ ចំនុចគួរចាប់អារម្មណ៍ គឺអ្នកភូមិជនបទមិនបានចាត់ទុករបប អនុគ្រោះនិយមនេះថាអយុត្តិធម៌ រឺមិនស្មើភាពនោះទេ (Ledgerwood and Vijghen 2002) ។ តួអង្គក្នុងក្បាលម៉ាស៊ីនរដ្ឋ ជាពិសេសមន្ត្រីរាជការ ត្រូវប្រឈមមុខនឹងគណនេយ្យភាពច្រើនបែបយ៉ាង ទាំងចំពោះគ្រួសារ និងអង្គការចាត់តាំងរបស់រដ្ឋ ។

## រដ្ឋប្រកាន់របបមេកើយ-កូនចៅសម័យថ្មី

ស្ថាប័នផ្លូវការត្រូវបានបង្កើតឡើងដើម្បីបំរើសាធារណៈជន និងគោរពតាមបែបបទគណនេយ្យភាពជាផ្លូវការ ប៉ុន្តែស្ថាប័នក្រៅផ្លូវការ (មនោគមវិជ្ជាបំរើនយោបាយ សីលធម៌និងបទដ្ឋានវប្បធម៌ បណ្តាញមេកើយ-កូនចៅជាប្រពៃណី) ប្រហែលអាចលំអៀងទៅរកផលប្រយោជន៍ឯកជន និងមានគណនេយ្យភាពមិនសូវច្បាស់លាស់ ។ ប្រព័ន្ធអភិបាលកិច្ចមេកើយ-កូនចៅសម័យថ្មី ជាប្រព័ន្ធចំរុះដែលក្នុងនោះវិធាននិងរបៀបរបបបែបមេកើយ-កូនចៅ វាស្ថិតនៅជាប់ពីក្រោមស្ថាប័នសមហេតុផល-ស្របច្បាប់នានា (Brinkerhoff and Goldsmith 2002) ។ ចរិតលក្ខណៈនៃរបបមេកើយ-កូនចៅសម័យថ្មី (ដែលជារបបមេកើយ-កូនចៅជាប្រពៃណីបានកែតំរូវ) រួមមាន (ក) ការដោះស្រាយបញ្ហាតាមវិធីពិសេសផ្ទាល់ខ្លួន (ខ) ការប្រមូលផ្តុំធនធានក្នុងដៃអ្នកឋានៈខ្ពស់មួយចំនួនតូច (គ) ការបែងចែកមិនច្បាស់លាស់រវាងដែនសាធារណៈ និងដែនឯកជន (ឃ) វត្តមានវិបត្តិហិរញ្ញវត្ថុរ៉ាំរ៉ៃ (Bratton and van de Walle 1994; van de Walle 2001) ។

ប្រព័ន្ធអភិបាលកិច្ចបច្ចុប្បន្នរបស់កម្ពុជា គឺមានបរិយាកាសនយោបាយ និងស្ថាប័នតាមបែបមេកើយ-កូនចៅសម័យថ្មី (Rusten *et al.* 2004) ដោយក្នុងនេះ បណ្តាញឧបត្ថម្ភគាំទ្រក្រៅផ្លូវការ បានជ្រៀតចូលទៅក្នុងស្ថាប័នផ្លូវការ ហើយធ្វើឱ្យទំនាក់ទំនងគណនេយ្យភាពវាស្មុគស្មាញជាខ្លាំង ។ ចរិតលក្ខណៈមួយនៃរបបមេកើយ-កូនចៅសម័យថ្មីនៅកម្ពុជា គឺការប្រើប្រាស់ជាប្រក្រតីនូវស្ថាប័នផ្លូវការសំរាប់ទាញយកផលប្រយោជន៍ ។ Huges (2003:61) បានលើកថា "រដ្ឋបានប្រើប្រាស់ហេតុផលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីបើកច្រកធនធាន ដែលបន្ទាប់មកក៏អាចយកវាមកប្រើប្រាស់សំរាប់ជំរុញលក្ខណៈពេញច្បាប់នៃរបបគ្រប់គ្រង តាមរយៈការផ្តល់អំណោយ និងតួនាទីដល់កូនចៅ ហើយពួកកូនចៅក៏បង្កើតសិទ្ធិអំណាច និងឱកាសសំរាប់កេងយកចំណេញ" ។ ដំណោះស្រាយផ្ទាល់ខ្លួនចំពោះបញ្ហាសាធារណៈ អាចមើលឃើញច្បាស់នៅពេលអ្នកភូមិជនបទក្រីក្រ បានអំពាវនាវដោយផ្ទាល់ដល់មន្ត្រីជាន់ខ្ពស់ឱ្យជួយដោះស្រាយបញ្ហារំលោភយកដីធ្លី ជាជាងដាក់បណ្តឹងតវ៉ាតាមរយៈស្ថាប័នការិយាធិបតេយ្យផ្លូវការរបស់រដ្ឋ ។ របបមេកើយ-កូនចៅសម័យថ្មី បានពង្រីកទៅដល់ថ្នាក់មូលដ្ឋាន ហើយនៅទីនោះមន្ត្រីការិយាល័យទទួលរងឥទ្ធិពលអវិជ្ជមាន ពីព្រោះបដិការមិនស្មើភាពនៅក្នុងទំនាក់ទំនង វាធ្វើឱ្យមានធនធានតិចតួចណាស់ (បានតែមួយរស់) ដែលធ្លាក់ទៅដល់ពួកគេ ។ ជារឿយៗធនធានដែលបែងចែកឱ្យនោះ វាបានត្រឹមតែ ជួយដោះស្រាយតំរូវការចាំបាច់របស់កូនចៅប៉ុណ្ណោះ ដើម្បីឱ្យកូនចៅនៅរក្សា ភក្តីភាព និងមានជីវភាពមួយដ៏សាមញ្ញបំផុត ។

កិច្ចពិភាក្សាខាងលើ ដែលផ្តោតលើទិដ្ឋភាពបច្ចេកទេសនិងក្រៅផ្លូវការនៃគណនេយ្យភាព បានលាតត្រដាងពីបរិយាកាសដ៏ស្មុគស្មាញ ដែលមន្ត្រីរាជការ និងអ្នកធ្វើកំណែទំរង់ ត្រូវបំពេញមុខងារខ្លួន ។ ដើម្បីជួយដល់មន្ត្រីរាជការ និងអ្នកធ្វើកំណែទំរង់ ក្នុងការងារវាយតំលៃលើប្រព័ន្ធអភិបាលកិច្ចដ៏ស្មុគស្មាញ អត្ថបទនេះដាក់ស្នើឡើងនូវនិយមន័យថ្មីមួយនៃគណនេយ្យភាព ដែលផ្សារភ្ជាប់ល្អទៅនឹងបរិបទកម្ពុជា ក៏ដូចជាការសន្មតផ្សេងៗខាងផ្នែកទ្រឹស្តី ។

## សេចក្តីសន្និដ្ឋាន

### ការកំណត់ឡើងវិញនូវនិយមន័យគណនេយ្យភាពក្នុងវិស័យសាធារណៈសំរាប់ប្រទេសកម្ពុជា

ដើម្បីពង្រឹងគណនេយ្យភាពក្នុងវិស័យសាធារណៈនៅកម្ពុជា ភ្នាក់ងាររដ្ឋបាលសាធារណៈ និងអ្នកធ្វើកំណែទំរង់ ចាំបាច់ត្រូវយល់ដឹងពីលក្ខណៈចាំបាច់ផ្សេងៗនៃគណនេយ្យភាព យោងតាមក្រឹត្យក្រមបច្ចេកទេស និងយោងតាម កត្តាសង្គមកិច្ចនិងកត្តានយោបាយជាក់ស្តែង ដែលជះឥទ្ធិពលជាលក្ខណៈក្រៅ ផ្លូវការទៅលើវា ។ ការយកចិត្តទុកដាក់មិនស្មើគ្នាចំពោះកត្តាទាំងពីរ ច្រើននាំឱ្យមានគណនេយ្យភាព "តែមួយជ្រុង" និងមានឱកាសតិចតួចដើម្បីនឹងផ្តល់សេវាសំខាន់ៗដោយមានចីរភាព ។ និយមន័យថ្មីតាមបរិបទនៃ គណនេយ្យភាព ដូចមាននៅខាងក្រោម ត្រូវបានរៀបចំឡើងដើម្បីឱ្យមាន តុល្យភាពស្របតាមតំរូវការ :

- គណនេយ្យភាព គឺជាសីលធម៌ផ្ទាល់ខ្លួន សីលធម៌ខាងរដ្ឋបាល និង

*តទៅទំព័រទី ១៩*